# សហព័ន្ធខ្មែរកម្ពុជាក្រោម

KHMERS KAMPUCHEA-KROM FEDERATION

Asia – Australia – Europe – North America

A member of IDBF & UNPO

Office of the Chairman | ការិយាល័យអធិបតី

No.1/KKF.Ch/17 | Date: 18/01/2017

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណា ខ្ញុំបាទ ក្នុងនាមអធិបតី នៃសហព័ន្ធខ្មែរកម្ពុជាក្រោម មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានឃើញអង្គសន្និបាតប្រចាំឆ្នាំ ២០១៦ របស់សហព័ន្ធខ្មែរកម្ពុជាក្រោម នៅទីក្រុង **Las Vegas** រដ្ឋ **Nevada** បានប្រព្រឹត្តទៅដោយភាពជោគជ័យ និងភាតរភាពជាលក្ខណៈមហាគ្រួសារខ្មែរក្រោមកាលពីថ្ងៃទី ១៣, ១៤, ១៥ ខែមករា ឆ្នាំ ២០១៧ កន្លងទៅនេះ ។

ការខិតខំប្រឹងប្រែងរបស់ ព្រះតេជព្រះគុណ និង ប្រធានសាខា សមាជិក សមាជិកា នៃសហព័ន្ធខ្មែរកម្ពុជាក្រោម នៅទីក្រុង **Las Vegas** បានជំរុញឱ្យសកម្មភាពសហព័ន្ធខ្មែរកម្ពុជាក្រោមទទួលបានលទ្ធផលយ៉ាងត្រចះត្រចង់សម្រាប់ការតស៊ូដោយអហិង្សា និងសិទ្ធិសេរីភាពលើឆាកអន្តរជាតិ ។

តាងនាមខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ និងអធិបតី នៃសហព័ន្ធខ្មែរកម្ពុជាក្រោម សូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រៅបំផុតចំពោះព្រះតេជព្រះគុណ និងលោក លោកស្រី ប្រធានសាខា សមាជិក សមាជិកា នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំទីក្រុង **Las Vegas** ដែលបានបំពេញករណីយកិច្ចរបស់ខ្លួនក្នុងស្មារតីមនសិការស្នេហាជាតិដ៏ឧត្តម ។

សូមព្រះតេជព្រះគុណ និងប្រធានសាខា សមាជិក សមាជិកា ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំព្រះករុណា ខ្ញុំបាទ ។

ទីក្រុងប៉ារីស ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៧

KHMERS KAMPUCHEA-KROM FEDERATION CHAIRMAN

**ថាច់ វៀន**

អធិបតី នៃសហព័ន្ធខ្មែរកម្ពុជាក្រោម

KKF - B.P. 69, 93423 – VILLEPINTE Cedex, France • Tel: + 33 1 43 83 51 87/ Fax: + 33 1 43 83 51 87
http://www.khmerkrom.net / www.khmerkrom.org • Email: vien.thach@khmerkrom.org